# កង់នៃប្រាជ្ញា
# Wheel of Wisdom

**សេចក្ដីសង្ខេប:**

ប្រាជ្ញានៅក្នុងព្រះគម្ពីរគឺជាការណែនាំរបស់ព្រះជាម្ចាស់សម្រាប់ការរស់នៅ។ យើងមានជីវិតដែលមានលំនឹង និងមានពរ នៅពេលដែលយើងប្រុងប្រយ័ត្នធ្វើតាមការណែនាំរបស់ព្រះអង្គសម្រាប់គ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។ មានទំនាក់ទំនងចម្បងបី គឺខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម ដែលកើតចេញជាទំនាក់ទំនងដទៃទៀតទាំងអស់។ ការស្គាល់ និងការអនុវត្តន៍តាមប្រាជ្ញានៅក្នុងព្រះគម្ពីរនៅក្នុងទំនាក់ទំនងនិមួយៗនេះនឹងនាំយើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង។

**គំនិតចម្បង:**

១. នៅពេលដែលបង្កើត ព្រះជាម្ចាស់បានប្រទានឱ្យយើងមានទំនាក់ទំនងចម្បងបី គឺព្រះជាម្ចាស់/ខាងវិញ្ញាណរបស់សព្វសារពើ/ខាងសាច់ឈាម និងមនុស្ស/ខាងសង្គម។
២. ព្រះជាម្ចាស់ប្រទានឱ្យយើងមានការណែនាំជាក់លាក់សម្រាប់ទំនាក់ទំនងនិមួយៗនេះ។ ការណែនាំនៅក្នុងបទគម្ពីរទាំងនេះត្រូវបានស្គាល់ថាជាប្រាជ្ញានៅក្នុងព្រះគម្ពីរ។
៣. ព្រះពរ និងលំនឹងនៅក្នុងជីវិតកើតឡើងពីការសម្រេចតាមការណែនាំរបស់ព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងទាំងអស់។
៤. យើងធ្វើដំណើរដោយនឹងនឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់ នៅពេលដែលយើងមានលំនឹងនៅក្នុងជីវិតរបស់យើង។
៥. ការធ្វេសប្រហែសចំពោះការណែនាំរបស់ព្រះជាម្ចាស់នាំមកនូវសេចក្ដីហិនវិនាស និងភាពគ្មានលំនឹងនៅក្នុងទំនាក់ទំនងមួយ ឬច្រើនរបស់យើង។

**លទ្ធផល:**

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយជាការឆ្លើយតបទៅនឹងគំនិតចម្បងនៅក្នុងមេរៀននេះ ដែលនាំមកនូវភាពមានលំនឹង និងប្រាជ្ញានៅក្នុងទំនាក់ទំនងទាំងអស់ ។

២. ទៅមុខទៀត

ក. ស្គាល់សេចក្តីត្រូវការឱ្យមានលំនឹងភាពនៅក្នុងទំនាក់ទំនងទាំងអស់របស់យើង កំណត់អត្តសញ្ញាណផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងមានបំណងខិតខំស្អាងផ្នែកទាំងនោះឡើង ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីប្រាប់ លើកទឹកចិត្ត និងបង្រៀនអ្នកជឿដទៃទៀតឱ្យអភិវឌ្ឍប្រាជ្ញា និងភាពមានលំនឹងនៅក្នុងទំនាក់ទំនងចម្បងនិមួយៗនេះ ។

ការសម្តែងរឿង

អ្នកពោលៈ ខ្ញុំចង់ឱ្យលោកអ្នកជួបមិត្តភក្តិបួននាក់ គឺសុជាតិខាងសាច់ឈាម សុខុមខាងសង្គម សុខនខាងប្រាជ្ញា និង សុខាខាងវិញ្ញាណ។

**តួអង្គសាច់ឈាមៈ** (សំដែងដូចជាអ្នកលើកសាច់ដុំ ដោយដំឡើងសាច់ដុំជានិច្ច)

ខ្ញុំគឺជាមនុស្សដែលប្រសើរជាងមុនឆ្ងាយណាស់ ពីព្រោះខ្ញុំមានរាងកាយដូចជាកីឡាករលើកសាច់ដុំដែលជាប់លេខ១។ ហាត់ប្រាណប្រាំមួយម៉ោងរាល់ថ្ងៃពិតជាអស្ចារ្យមែនទែន! ប្រពន្ធរបស់ខ្ញុំបានទៅរស់នៅជាមួយម្តាយរបស់នាងវិញ ដើម្បីឱ្យមានគ្នានិយាយលេង ដូច្នេះឥឡូវនេះ ខ្ញុំមានពេលច្រើនជាងមុន។ ខ្ញុំបានថែមកីឡារត់មួយទៀតទៅក្នុងកាលវិភាគរបស់ខ្ញុំ។ ខ្ញុំមានរាងកាយដែលល្អណាស់! មនុស្សគ្រប់គ្នាគួរតែដូចជាខ្ញុំ!

**ផ្នែកសង្គមៈ** (សប្បាយចិត្ត សើច ធ្វើពុតជានិយាយជាមួយមិត្តភក្តិជាច្រើន)

ខ្ញុំមានមិត្តភក្តិច្រើនណាស់ ខ្ញុំសប្បាយចិត្តខ្លាំងណាស់។ ខ្ញុំមានគម្រោងធ្វើពិធីជប់លៀងធំមួយនៅផ្ទះរបស់ខ្ញុំនៅចុងសប្តាហ៍នេះ ហើយសូមអញ្ជើញអ្នកទាំងអស់គ្នាមកចូលរួម! អូហ៎ កុំភ្លេច នាំមិត្តភក្តិម្នាក់មកជាមួយផង! ទេ ខ្ញុំមិនមានពេលទៅចូលរួម (ដាក់ចូលឈ្មោះការជួបប្រជុំ ឬសន្និបាតនៅថ្ងៃនេះ)ជាមួយឯងបានទេ ប៉ុន្តែអរគុណហើយ! ប្រហែលជាខ្ញុំនឹងទៅព្រះវិហារនៅពេលបុណ្យណូអែល! ទាយទៅមើល តើខ្ញុំធ្វើអ្វីទៀត? នៅសប្តាហ៍ក្រោយ ខ្ញុំនឹងទៅមហោស្រព ទៅមើលការប្រគុំតន្ត្រី និងមានពិធីជប់លៀងមួយផ្សេងទៀត ហើយ...!

**ផ្នែកប្រាជ្ញាៈ** (បង្ហាញប្រាជ្ញាខ្ពង់ខ្ពស់ ធ្វើឱ្យមនុស្សចាប់អារម្មណ៍ថាជាអ្នកមានចំណេះ)

តើអ្នកដឹងថា ព្រះអាទិត្យធំជាងផែនដីដល់ទៅ១០៩ដងដែរឬទេ? តើអ្នកដឹងថា សីតុណ្ហភាពនៅព្រះអាទិត្យ ផ្ទៃខាងក្រៅគឺប្រហែលជា៦០០០ សែលស៊ីស តែនៅខាងក្នុងវិញអាចដល់ ១៣០០០ សែលស៊ីសដែរឬទេ? ខ្ញុំឆ្លាតខ្លាំងណាស់ កម្រិតប្រាជ្ញារបស់ខ្ញុំគឺ ១៨៥ ធ្វើឱ្យខ្ញុំក្លាយជាមនុស្សដែលអច្ឆរិយៈ! មនុស្សគ្រប់គ្នាគួរតែដូចខ្ញុំ ដើម្បីឱ្យពិភពលោកអាចរីកចម្រើនឡើងមួយកម្រិតថែមទៀត (បន្ទាប់មក ធ្វើទឹកមុខព្រួយ)។ បន្ទាប់មក ខ្ញុំប្រហែលអាចមានមិត្តភក្តិខ្លះ...

**ផ្នែកខាងវិញ្ញាណៈ** (ច្រៀង)

"បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ...មែនហើយ ខ្ញុំជាមនុស្សបរិសុទ្ធ"។ ខ្ញុំស្រលាញ់ព្រះខ្លាំងណាស់! ខ្ញុំនៅព្រះវិហារពេញមួយសប្តាហ៍។ រៀងរាល់ថ្ងៃ ខ្ញុំអធិស្ឋានប្រាំមួយម៉ោង ហើយមួយសប្តាហ៍ ខ្ញុំតមបួនថ្ងៃ ប៉ុន្តែខ្ញុំត្រូវគេបៀតបៀនខ្លាំងណាស់។ គ្រូគង្វាល និងអ្នកដឹកនាំមិនគោរពខ្ញុំទេ! ពួកគេជំទាស់នឹងគំនិតរបស់ខ្ញុំទាំងអស់! ពួកគេមានគោលលទ្ធិខុសឆ្គង! (ភ្លាមនោះ ស្រាប់តែខឹងយ៉ាងខ្លំង) តើពួកគេគិតថា ពួកគេគឺជានរណា? តើពួកគេមានសិទ្ធិអ្វីនឹងរិះគន់ខ្ញុំ? (ភ្លាមនោះ ស្រប់តែបរិសុទ្ធវិញ) "ឱ ព្រះវរបិតាអើយ សូមអត់ទោសឱ្យពួកគេផង ដ្បិតពួកគេមិនដឹងថា ពួកគេធ្វើអ្វីទេ..." (ច្រៀង) " បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ...មែនហើយ ខ្ញុំជាមនុស្សបរិសុទ្ធ"

- ***ប្រាប់តួអង្គឱ្យសម្រាកលំហែមួយរយៈនៅក្នុងការសំដែងតួរបស់ពួកគេ ក្រោយពីណែនាំខ្លួនរួចហើយ។ ពួកគេនិយាយ នៅពេលដំណាលគ្នា មិនយកចិត្តទុកដាក់ស្តាប់គ្នាទៅវិញទៅមកទេ។***
- ***បញ្ឈប់"ការសន្ទនា"របស់ពួកគេ អរគុណពួកគេដែលបានចូលរួម និងថ្លែងបញ្ចប់ដូចខាងក្រោមៈ***

**អ្នកពោលៈ** នៅពេលដែលយើងបាននិយាយអំពីលូកា ២:៥២ យើងបានឮថា ព្រះយេស៊ូវបានចម្រើនឡើងខាងសាច់ឈាម ខាងវិញ្ញាណ ខាងសង្គម និងខាងប្រាជ្ញា។ បន្ទាប់មក យើងបានជួបជាមួយមិត្តភក្តិបួននាក់នេះ។ ពួកគេម្នាក់ៗបានចម្រើនឡើងនៅក្នុងផ្នែកមួយ ទោះបីជាមិនតាមរបៀបដែលយើងបានសិក្សាក៏ដោយ។

ក្រោយពីបានជួបជាមួយពួកគេរួចហើយ យើងមានហេតុផលល្អៗមួយចំនួន ដើម្បីរៀនអំពីភាពមានលំនឹងនៅក្នុងការវិវឌ្ឍន៍។

# គន្លឹះនៃប្រាជ្ញា
## ក្រោយមេរៀន

## ១. រំឭកមេរៀនឡើងវិញ

## ២. សេចក្ដីផ្ដើម — "មិត្តភក្ដិបីនាក់"

ក. តើលោកអ្នកបានមើលឃើញអ្វីនៅក្នុងការសម្ដែងរឿង?

ខ. តើតួអង្គខ្វះខាតអ្វី? តើពួកគេមានប្រាជ្ញាដែរឬទេ? តើពួកគេមានលំនឹងដែរឬទេ?

គ. ហេតុអ្វីបានជាតួអង្គទាំងនេះពិបាកនឹងស្ដាប់គ្នាទៅវិញទៅមក? ហេតុអ្វីបានជាពួកគេពិបាកនឹងបម្រើអ្នកដទៃទៀត?

## ៣. ខគម្ពីរគន្លឹះ: ទំនុកដំកើង ១១១:១០

ក. តើនរណាគឺជាប្រភពនៃប្រាជ្ញា?

ខ. អ្នកដែលកាន់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់មាន "យោបល់ល្អ" ។ តើលោកអ្នកគិតថា ពួកគេមានយោបល់ល្អអំពីអ្វី?

គ. តើយើងគួរតែធ្វើតាមការណែនាំរបស់ព្រះអង្គនៅក្នុងផ្នែកណាមួយនៃជីវិត? តើប្រាជ្ញារបស់ព្រះអង្គអាចមានឥទ្ធិពលលើការប្រព្រឹត្តិ ទំនាក់ទំនង និងការសម្រេចចិត្តរបស់យើងយ៉ាងដូចម្ដេច?

## ៤. ទំនាក់ទំនងចម្បងបី

*លោកុប្បត្តិ ១:២៦* *លោកុប្បត្តិ ២:៨* *លោកុប្បត្តិ ២:១៨*

- តើទំនាក់ទំនងចម្បងបីដែលព្រះជាម្ចាស់បានប្រទានដល់យើង ពេលដែលព្រះអង្គបានបង្កើតមនុស្សនោះមានអ្វីខ្លះ?
- តើពាក្យសាមញ្ញសម្រាប់ទំនាក់ទំនងទាំងនេះមានពាក្យអ្វីខ្លះ? តើលោកអ្នកមើលឃើញមួយណានៅក្នុងបទគម្ពីរនិមួយៗ?
- តើលោកអ្នកនឹងឱ្យនិយមន័យទំនាក់ទំនងទាំងនេះយ៉ាងដូចម្តេច? ឧទាហរណ៍ ទំនាក់ទំនងខាងសង្គមគឺជាទំនាក់ទំនងរបស់យើងជាមួយ ____________________?
- តើឧទាហរណ៍មួយចំនួនអំពីទំនាក់ទំនងខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម មានអ្វីខ្លះ?

## ៥. តើប្រាជ្ញាគឺជាអ្វី?

ក. សូមអាន: *ទំនុក ១១១:១០* *សុភា ២:៥* *១ កូរិន ១:២៣-២៤* *យ៉ាកុប ៣:១៣, ១៧*

- តើការស្តាប់បង្គាប់មានទំនាក់ទំនងជាមួយប្រាជ្ញាយ៉ាងដូចម្តេច?

- តើលក្ខណៈរបស់ប្រាជ្ញាដែលអាចសង្កេតឃើញនៅក្នុងជីវិតរបស់យើង មានអ្វីខ្លះ?

ខ. សូមអាន: *ទំនុក ១១៩:៩៧-១០០* *សុភា ២:៦* *២ធីម៉ូ ៣:១៦* *១កូរិន ២:៦-៧, ១២-១៣*

- តើប្រាជ្ញាមកពីណា?

- ហេតុអ្វីបានជាមានប្រាជ្ញាសំខាន់?

គ. សូមអាន: *សុភា ២:៩-១២* *សុភា ៣:១-២* *សុភា ៤:៥-៧* *កូល៉ុស ១:៩-១២* *ចោទិ ២៨:២-៦* ៣០:១៥-១៦

- តើប្រាជ្ញាមានគុណតម្លៃយ៉ាងដូចម្តេច?

- តើលក្ខខណ្ឌដើម្បីទទួលបានផលប្រយោជន៍ទាំងនេះ គឺជាអ្វី?

**៦. ប្រាជ្ញា និងទំនាក់ទំនងទាំងបី ~ តើប្រាជ្ញា និងទំនាក់ទំនងចម្បងទាំងបីដែលព្រះជាម្ចាស់បានប្រទានឱ្យយើងមានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្ដេច?**

**៧. ព្រះជាម្ចាស់ដាក់យើងនៅក្នុងទំនាក់ទំនងទាំងនេះដោយមានគោលបំណង** ~ តើព្រះជាម្ចាស់បានប្រទានឱ្យយើងមានការទទួលខុសត្រូវអ្វីខ្លះនៅក្នុងទំនាក់ទំនងនិមួយៗនេះ?

ក. ខាងវិញ្ញាណ

ខ. ខាងសង្គម

គ. ខាងសាច់ឈាម

## ៨. កង់នៃប្រាជ្ញា

ក. តើមានអ្វីកើតឡើង នៅពេលដែលកាំទាំងបីរឹងមាំ ហើយខ្ទងកង់មូល?




ខ. កង់ដែលមូល ហើយមានលំនឹងកំពុងវិលឆ្ពោះទៅរកអ្វីមួយ ។ តើគឺជាអ្វី?



គ.  តើប្រាជ្ញាជួយយើងធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់ នៅក្នុងទំនាក់ទំនងទាំងអស់ ទាំងខាងវិញ្ញាណ ខាងសាច់ឈាម និងខាង សង្គមយ៉ាងដូចម្តេច?

ឃ. តើមានអ្វីកើតឡើងចំពោះចលនារបស់កង់ ពេលដែលខូច ឬបាត់ខ្នងកង់?




ង.  តើមានលទ្ធផលអ្វីមកលើកង់ ពេលដែលកាំមួយទន់ បាក់ ឬបាត់?

## ៩.  ការពង្រឹងគំនិតគន្លឹះឡើងវិញ

## ១០. ការអនុវត្តន៍

ក. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

- តើកង់របស់លោកអ្នក (ជីវិតរបស់លោកអ្នក) យ៉ាងដូចម្តេចដែរ? តើមានលំនឹងដែរឬទេ? តើខ្ទង់កង់យ៉ាងដូចម្តេចដែរ? តើកង់មានចលនាឆ្ពោះទៅមុខដែរឬទេ?

- តើផ្នែកណាខ្លះនៅក្នុងជីវិត និងការបម្រើរបស់លោកអ្នកដែលត្រូវអភិវឌ្ឍឱ្យប្រសើរជាងមុន ឬឱ្យកាន់តែមានលំនឹងថែមទៀត?

| ប្រាជ្ញាត្រូវការនៅក្នុងជីវិតរបស់ខ្ញុំ | | | |
|---|---|---|---|
| សម្រាប់ផ្នែកនិមួយៗខាងក្រោម សូមប្រាប់ឧទាហរណ៍មួយអំពីរបៀបរីកចម្រើនឡើងខាងឯប្រាជ្ញានៅក្នុងទំនាក់ទំនងនិមួយៗនៃទំនាក់ទំនងទាំងបីនេះ។ | | | |
| ផ្នែកអភិវឌ្ឍ | ខាងសាច់ឈាម | ខាងវិញ្ញាណ | ខាងសង្គម |
| ជីវិតរបស់ខ្ញុំ | | | |

ខ. ផែនការអនុវត្ត

- ជ្រើសរើសជំហានជាក់លាក់មួយដែលលោកអ្នកអាចធ្វើបាន ដើម្បីរីកចម្រើនឡើង និងកាន់តែវិវឌ្ឍប្រសើរឡើង និងកាន់តែមានលំនឹងឡើងនៅក្នុងទំនាក់ទំនងរបស់លោកអ្នក។

<table>
<tr><th colspan="2">ផែនការអនុវត្តបម្រើអ្នកដទៃទៀត និងការប្តេជ្ញាចិត្ត</th></tr>
<tr><td colspan="2">ចូរសរសេរផែនការជាក់លាក់មួយសម្រាប់ជំហានមួយដែលលោកអ្នកនឹងធ្វើនៅពេលឆាប់ៗ ដើម្បីរីកចម្រើនឡើងខាងឯប្រាជ្ញានៅក្នុងទំនាក់ទំនងមួយរបស់លោកអ្នក ។</td></tr>
<tr><td>ខាងសាច់ឈាម</td><td rowspan="3">អ្វី?<br><br>នរណា?<br><br>នៅកន្លែងណា?<br><br>នៅទីណា?</td></tr>
<tr><td>ខាងវិញ្ញាណ</td></tr>
<tr><td>ខាងសង្គម</td></tr>
</table>

- ប្តេជ្ញាចិត្តធ្វើជំហាននោះ ។
- ចែកចាយផែនការរបស់លោកអ្នកជាមួយអ្នកផ្សេងទៀត និងអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក ។

# គន់នៃប្រាជ្ញា
## មេរៀន

### តើប្រាជ្ញាគឺជាអ្វី?

យើងបានមើលឃើញនៅក្នុងលូកា ២:៥២ ថា ព្រះយេស៊ូវបានរីកចម្រើនឡើងខាងប្រាជ្ញា ហើយយើងបានគិតថា ព្រះអង្គគឺជាគំរូដែលល្អជាងគេបំផុតសម្រាប់ការរីកចម្រើន និងការវិវឌ្ឍន៍ឡើងរបស់យើង។ ដូច្នេះហើយ យើងគួរតែរីកចម្រើនឡើងខាងប្រាជ្ញាផងដែរ ប៉ុន្តែដំបូងយើងត្រូវឱ្យនិយមន័យប្រាជ្ញាជាមុនសិន! ប្រាជ្ញានេះមិនដូចជាការរីកចម្រើនឡើងខាងបញ្ញា ឬស្មារតីនឹងនទេ។ សរុបមក ប្រាជ្ញានៅក្នុងព្រះគម្ពីរគឺជាការស្គាល់ និងធ្វើតាមអ្វីដែលព្រះជាម្ចាស់បង្គាប់។ ប្រាជ្ញានៅក្នុងព្រះគម្ពីរគឺជាការរស់នៅតាមការណែនាំរបស់ព្រះជាម្ចាស់នៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

វប្បធម៌ហេព្រើរកាលពីបុរាណល្បីល្បាញខាងប្រមូលពាក្យស្លោក និងអក្សរសាស្ត្រទាក់ទងនឹងប្រាជ្ញា ដែលយើងរកបានជាចម្បងនៅក្នុងកណ្ឌគម្ពីរសុភាសិត និងទំនុកដំកើង។ កណ្ឌគម្ពីរប្រាជ្ញាបានប្រាប់មនុស្សអំពីរបៀបធ្វើឱ្យព្រះជាម្ចាស់សព្វព្រះហឫទ័យ និងរបៀបរស់នៅឱ្យបានល្អ។ ក្មេងប្រុសជនជាតិយូដានៅសម័យព្រះយេស៊ូវមានទម្លាប់ទន្ទេញពាក្យស្លោកទាក់ទងនឹងប្រាជ្ញា ដើម្បីឱ្យពួកគេអាចរីកចម្រើនឡើងបានខាងឯប្រាជ្ញា។

ព្រះយេស៊ូវបានធ្វើដូច្នោះ ហើយយើងគួរតែធ្វើយ៉ាងដូច្នោះដែរ។ គេត្រូវស្វែងរកប្រាជ្ញាឱ្យដូចជាត្បូងមានតម្លៃ ហើយនៅពេលដែលយើងដើរតាមផ្លូវរបស់ព្រះអង្គ និងកាន់តាមបញ្ញត្តិរបស់ព្រះអង្គ កណ្ឌគម្ពីរប្រាជ្ញានៅក្នុងព្រះគម្ពីរប្រាប់ថា វានាំឱ្យយើងមានជីវិត វិបុលភាព និងព្រះពរ។ ពាក្យស្លោកប្រកបដោយប្រាជ្ញាជាច្រើននៅក្នុងព្រះគម្ពីរបង្ហាញប្រាប់យើងអំពីរបៀបចម្រើនឡើងខាងឯសេចក្តីស្មោះត្រង់ យុត្តិធម៌ ដឹងខ្នាត សេចក្តីសុចរិត ការបន្ទាបខ្លួន សហគមន៍ និងសប្បុរសធម៌។ មែនហើយ យើងគួរតែស្វះស្វែងដើម្បីឱ្យបានស្គាល់ និងរស់នៅតាមប្រាជ្ញានេះ!

ប្រភពនៃប្រាជ្ញាទាំងអស់គឺជាព្រះជាម្ចាស់។ ព្រះអង្គបានបង្កើតយើងមក ហើយព្រះអង្គដឹងរបៀបដើម្បីឱ្យជីវិតមានសុភមង្គលបំផុត។ ប្រាជ្ញារបស់ព្រះអង្គគួរតែមានឥទ្ធិពលលើការប្រព្រឹត្ត ការសេពគប់ ការទំនាក់ទំនង និងការសម្រេចចិត្តរបស់យើង។ គេអាចរកឃើញការអំពាវនាវឱ្យស្វែងរកប្រាជ្ញានៅក្នុងសុភាសិត ៤:៥-៧:

ចូរខំឱ្យបានប្រាជ្ញា ចូរខំឱ្យបានយោបល់

កុំឱ្យភ្លេចឡើយ ក៏កុំឱ្យបែរចេញពីពាក្យដែលមាត់អញពោលដែរ

កុំឱ្យចោលប្រាជ្ញាឡើយ នោះនឹងការពារឯង
ចូរស្រឡាញ់ប្រាជ្ញាចុះ នោះនឹងទំនុកបំរុងឯង
ប្រាជ្ញាជាសំខាន់លេខ១ ដូច្នេះចូរខំឱ្យបានប្រាជ្ញាចុះ
អើ កំពុងដែលខំឱ្យបានរបស់ផ្សេងៗ
នោះចូរខំឱ្យបានយោបល់ផង។

ទោះបីជាយើងប្រហែលជាបានរៀនប្រាជ្ញារបស់ព្រះជាម្ចាស់តាមរយៈអ្នកដែលមានប្រាជ្ញា ឬពាក្យស្លោកប្រកបដោយប្រាជ្ញាក៏ដោយ ព្រះគម្ពីរគឺជាប្រភពនៃប្រាជ្ញារបស់ព្រះជាម្ចាស់សម្រាប់យើងនៅសព្វថ្ងៃនេះ។ ព្រះគម្ពីរមានការណែនាំរបស់ព្រះជាម្ចាស់ ហើយការស្តាប់បង្គាប់តាមការណែនាំទាំងនោះជួយយើងឱ្យរស់នៅបានយ៉ាងល្អ។ ព្រះគម្ពីរគឺជាការបើកសំដែងរបស់ព្រះជាម្ចាស់សម្រាប់របៀបរស់នៅ សម្រាប់ព្រះពរ និងសម្រាប់ការប្រោសយើងឱ្យជា។ ផលិតផលជាច្រើនមានសៀវភៅណែនាំអំពីការប្រើប្រាស់ គឺជាការណែនាំសរសេរឡើងដោយអ្នករចនាផលិតផល ឬក្រុមហ៊ុនដែលផលិត។ អ្នករចនា និងក្រុមហ៊ុនដែលផលិតគឺជាអ្នកស័ក្តិសមបំផុតនឹងសរសេរសៀវភៅណែនាំ។ ពួកគេដឹងរបៀបដែលផលិតផលរបស់ពួកគេត្រូវបានបង្កើតឡើង និងរបៀបគួរប្រើឱ្យត្រូវតាមបំណងរបស់ពួកគេ។ ព្រះជាម្ចាស់គឺជាអ្នកបង្កើតយើង ការបើកសំដែងជាលាយលក្ខណ៍អក្សររបស់ព្រះអង្គ គឺព្រះគម្ពីរ ប្រៀបបីដូចជាសៀវភៅណែនាំអំពីការប្រើប្រាស់សម្រាប់យើង។ តាមរយៈព្រះគម្ពីរ ព្រះអង្គប្រាប់យើងអំពីរបៀបដែលព្រះអង្គបានរចនាយើងឡើងឱ្យដំណើរការ ឬរស់នៅតាមគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

## ទំនាក់ទំនងចម្បងទាំងបី

ព្រះជាម្ចាស់មិនត្រឹមតែបានបង្កើតយើង និងរបស់សព្វសារពើប៉ុណ្ណោះទេ ព្រះអង្គថែមទាំងដាក់ឱ្យយើងមានទំនាក់ទំនងចម្បងបី ជាមួយព្រះអង្គ ជាមួយមនុស្សដទៃទៀត និងជាមួយស្នាព្រះហស្តផ្សេងទៀត។ នៅពេលធ្លាក់ចុះទំនាក់ទំនងទាំងអស់នេះបានបាក់បែក (លោកុប្បត្តិ ៣:១២-១៩)។ យើងរកឃើញការណែនាំ គោលការណ៍ និងប្រាជ្ញាដើម្បីប្រោសភាពបាក់បែករបស់យើងឱ្យជានៅក្នុងព្រះគម្ពីរ។ នៅក្នុងសៀវភៅនេះ ព្រះជាម្ចាស់បានបើកសំដែងឱ្យឃើញរបៀបដែលជីវិតផ្ទាល់ខ្លួនរបស់យើង និងសហគមន៍របស់យើងអាចត្រូវបានប្រោសឱ្យជា នៅពេលដែលបាក់បែក និងរបៀបដែលយើងអាចរីកចម្រើនឡើងបាន។ ហេតុអ្វីបានជាយើងមិនចង់រស់នៅតាមប្រាជ្ញាវាងវៃបំផុតរបស់អ្នកបង្កើតយើង?

សូមឱ្យខ្ញុំបញ្ជាក់ជូនចំណុចមួយចំនួន។ យើងបាននិយាយថា នៅពេលដែលបង្កើតលោក ព្រះជាម្ចាស់បានដាក់ឱ្យមនុស្សមានទំនាក់ទំនងចម្បងបី មានខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម។ ទំនាក់ទំនងទាំងនេះស្ដាប់មើលទៅដូចជាផ្នែកនៃការរីកចម្រើនឡើងរបស់ព្រះយេស៊ូវដែរ។ តើយើងចង់មានន័យដូចម្ដេច តាមរយៈពាក្យ "ចម្បង"? ទាំងនេះគឺជាទំនាក់ទំនងចម្បង ពីព្រោះទំនាក់ទំនងដទៃទៀតទាំងអស់ដែលព្រះជាម្ចាស់បានប្រទានឱ្យមនុស្សពឹងផ្អែកលើទំនាក់ទំនងទាំងបីនេះ។ ទំនាក់ទំនងទាំងបីនេះគឺជាមូលដ្ឋានគ្រឹះសំខាន់បំផុតនៅក្នុងទំនាក់ទំនងទាំងអស់របស់យើង។

សូមឱ្យខ្ញុំបញ្ជាក់ពីអត្ថន័យដែលយើងចង់មានន័យ និងមិនចង់មានន័យតាមរយៈពាក្យ "ទំនាក់ទំនង"។ ទំនាក់ទំនងលើសពីការរាប់អាន ដែលមនុស្សទូទៅយល់ថាជាទំនាក់ទំនង។ ជាធម្មតា នៅពេលដែលយើងរាប់អានមនុស្សដទៃទៀត យើងនិយាយថា យើងកំពុងតែទំនាក់ទំនងក្នុងសង្គមជាមួយពួកគេ។ នៅពេលដែលយើងដឹងថា មានព្រះវត្តមានរបស់ព្រះជាម្ចាស់ យើងនិយាយថា យើងកំពុងតែទំនាក់ទំនងខាងវិញ្ញាណជាមួយព្រះអង្គ។ មនុស្សជាច្រើននិយាយថា ពួកគេមានទំនាក់ទំនងល្អជាមួយសត្វ។ អ្នកខ្លះនិយាយថា ពួកគេ "ប្រកបគ្នាជាមួយធម្មជាតិ" មានន័យថា ពួកគេមានភាពសុខសាន្ត ពេលដែលហ៊ុមព័ទ្ធជុំវិញដោយសោភ័ណភាព និងភាពស្ងប់ស្ងាត់របស់ធម្មជាតិ។ នៅពេលដែលនិយាយអំពីទំនាក់ទំនង តាមធម្មតាយើងចង់មានន័យថា យើងប្រស្រ័យទាក់ទងជាមួយពិភពសង្គម ពិភពវិញ្ញាណ និងពិភពសាច់ឈាម។

ប៉ុន្តែការប្រស្រ័យទាក់ទងមិនទាន់ដល់អត្ថន័យដែលយើងចង់មានន័យអំពីទំនាក់ទំនងទាំងបី ដែលព្រះជាម្ចាស់បានប្រទានឱ្យយើង នៅពេលដែលព្រះអង្គបានបង្កើតលោកនោះទេ។ ទំនាក់ទំនងចម្បងទាំងបីដែលព្រះជាម្ចាស់បានប្រទានឱ្យយើង មិនត្រឹមតែពាក់ព័ន្ធសមត្ថភាពរបស់យើងនៅក្នុងការប្រស្រ័យទាក់ទងគ្នាជាមួយស្នាព្រះហស្តដទៃទៀតប៉ុណ្ណោះទេ ថែមទាំងពាក់ព័ន្ធដល់តួនាទី ការទទួលខុសត្រូវ ការមើលការខុសត្រូវ និងសិទ្ធិអំណាច និងតួនាទីរបស់យើងពាក់ព័ន្ធនឹងស្នាព្រះហស្តដទៃទៀតរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនបានបង្កើតពិភពលោកមក ហើយដាក់យើងនៅក្នុងពិភពលោក ដូចជាកូនក្រមុំតុក្កតានៅក្នុងពិភពក្មេងលេងនោះទេ។ ផ្ទុយទៅវិញ ព្រះអង្គបានប្រទានឱ្យយើងមានការទទួលខុសត្រូវ តួនាទី និងការរួមចំណែក។ ព្រះអង្គបានដាក់ឱ្យយើងមាន "ទំនាក់ទំនង" ជាមួយស្នាព្រះហស្តដែលព្រះអង្គបានបង្កើត។

ឧទាហរណ៍មួយចំនួនអំពីអត្ថន័យនេះមាន: *ទំនាក់ទំនងខាងវិញ្ញាណ* រួមមានទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ និងពិភពខាងវិញ្ញាណ គឺជាមួយព្រះវរបិតា ព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធ ពួកជំនុំ និងផ្សេងទៀតនៅក្នុងពិភពខាងវិញ្ញាណ (ទេវតា ពួកវិញ្ញាណអាក្រក់ អារក្សសាតាំង)។ នៅក្នុងផ្នែកខាងវិញ្ញាណ ការទទួលខុសត្រូវមួយរបស់

យើងគឺនៅជាប់នឹងព្រះគ្រីស្ទ។ *ទំនាក់ទំនងខាងសង្គម* រួមមានទំនាក់ទំនងរបស់យើងជាមួយគ្នាទៅវិញទៅមក គឺជាមួយគ្រួសារ មិត្តភក្តិ អ្នកជិតខាង សហគមន៍ រដ្ឋាភិបាល ប្រធាន អ្នករួមការងារ និងសូម្បីតែខ្មាំងសត្រូវរបស់យើង។ នៅក្នុងផ្នែកនេះ អ្នកដែលជាប្តី និងជាឪពុកមានការទទួលខុសត្រូវមើលថែ ស្រលាញ់ និងយកចិត្តទុកដាក់ចំពោះគ្រួសាររបស់ខ្លួន។ *ទំនាក់ទំនងខាងសាច់ឈាម* រួមមានទំនាក់ទំនងរបស់យើងជាមួយស្នាព្រះហស្តខាងសាច់ឈាម គឺជាមួយរូបកាយ ការងារ សត្វ និងពេលវេលារបស់យើង។ នៅក្នុងផ្នែកនេះ ការទទួលខុសត្រូវមួយចំនួនរបស់យើងគឺមើលថែបរិដ្ឋានរបស់យើងឱ្យបានស្អាត ឬការងារ អនុញ្ញាតឱ្យដីសម្រាកក្រោយពីដាំដុះបានប្រាំពីរឆ្នាំហើយ សម្រាកនៅថ្ងៃទីប្រាំពីរ ។ល។

មែនហើយ ព្រះជាម្ចាស់បានប្រទានឱ្យយើងមានទំនាក់ទំនងចម្បងទាំងបីនេះ ហើយព្រះអង្គក៏បានប្រទានឱ្យយើងផងដែរនូវការណែនាំដ៏ជាក់លាក់សម្រាប់ទំនាក់ទំនងនិមួយៗនេះ។ ការណែនាំនៅក្នុងបទគម្ពីរទាំងនេះត្រូវបានគេស្គាល់ថាជាប្រាជ្ញានៅក្នុងព្រះគម្ពីរ។ ការស្គាល់ និងការអនុវត្តន៏ប្រាជ្ញានៅក្នុងព្រះគម្ពីរនៅតាមទំនាក់ទំនងនិមួយៗនេះនឹងនាំយើងឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិត គឺជាជីវិតដែលរស់នៅតាមបំណងរបស់អ្នកដែលបានរចនាយើងមក។

## **កង់នៃប្រាជ្ញា**

យើងយកកង់មួយមកពន្យល់អំពីទំនាក់ទំនងទាំងបី និងតួនាទីរបស់ប្រាជ្ញានៅក្នុងការនាំមនុស្សឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់។ ខ្នងកង់តំណាងឱ្យប្រាជ្ញា។ ដុំដែលនៅកណ្តាលតំណាងឱ្យជីវិតរបស់យើង។ កាំតំណាងឱ្យទំនាក់ទំនងចម្បងទាំងបី[១]។ នៅក្នុងរូបភាពពន្យល់របស់យើង កង់កំពុងរៀបចំធ្វើចលនាទៅមុខ ឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិត។ ឥឡូវនេះ ស្រមៃមើលរូបភាពកង់នេះខូច។ ប្រហែលជាខ្នងកង់វៀច ឬអត់មានកាំកង់វៀច ឬបាក់។ នៅក្នុងស្ថានភាពខូចនេះ កង់មានចលនាទៅមុខមិនស្រួលទេ! បន្ទាប់មកទៀត ស្រមៃមើលរូបភាពកង់ដែលល្អវិញ។ ខ្នងកង់មូល ដុំនៅចំកណ្តាល កាំកង់ត្រង់ និងមានលំនឹង។ តើលោកអ្នកនឹងប្រើកង់មួយណា? តើលោកអ្នកនឹងជិះកង់មួយណា? តើកង់មួយណាតំណាងឱ្យជីវិតរបស់លោកអ្នក?

[1] មនុស្សមួយចំនួនពិភាក្សាអំពីទំនាក់ទំនងទីបួន គឺទំនាក់ទំនងរបស់យើងជាមួយខ្លួនឯង។ នៅត្រង់នេះ យើងលប់ចោលពីព្រោះបទគម្ពីរដាស់តឿនយើងកុំឱ្យផ្តោតលើខ្លួនឯង និងដោយព្រោះអារម្មណ៍នឹងធឹង និងភាពមានលំនឹងផ្ទាល់ខ្លួន ជាញឹកញាប់កើតចេញពីការស្តាប់បង្គាប់នៅក្នុងទំនាក់ទំនងខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម។

កង់ពិបាកប្រើខ្លាំងណាស់ ប្រសិនបើខ្វះខ្នងកង់ បាត់កាំ កាំទន់ ឬបាក់ ឬប្រសិនបើដុំមិននៅចំកណ្តាល។ នេះប្រៀបបីដូចជាជីវិតដែលមិនមានលំនឹង។ កង់ដែលពេញលក្ខណៈ ហើយមានលំនឹងអាចសម្រេចគោលបំណងដែលគេបង្កើតវាមក គឺកង់អាចធ្វើចលនាឆ្ពោះទៅរកគោលដៅរបស់ខ្លួនបានយ៉ាងងាយស្រួល។ នៅពេលដែលមានលំនឹង ជីវិតរបស់យើងអាចធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់យើង និងអ្នកដែលយើងបានបម្រើ។ យើងត្រូវរស់នៅឱ្យចំកណ្តាលប្រាជ្ញារបស់ព្រះជាម្ចាស់ ដោយធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គនៅក្នុងទំនាក់ទំនងទាំងបីនេះ។

ប្រាជ្ញាតំណាងដោយខ្នងកង់ដែលទ្រទាំងអស់ គឺជាការស្គាល់ និងការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម។ ប្រសិនបើយើងស្គាល់ ហើយស្តាប់បង្គាប់តាមប្រាជ្ញារបស់ព្រះជាម្ចាស់សម្រាប់ទំនាក់ទំនងខាងសាច់ឈាម ខាងវិញ្ញាណ និងខាងសង្គមរបស់យើង យើងមានលំនឹង ហើយធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គសម្រាប់ជីវិតរស់នៅ និងការបម្រើរបស់យើង។ ប្រសិនបើយើងជួយអ្នកផ្សេងឱ្យរីកចម្រើនឡើងខាងប្រាជ្ញា យើងជួយគេឱ្យស្គាល់ និងធ្វើតាមការណែនាំរបស់ព្រះជាម្ចាស់ ដោយធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គសម្រាប់គ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។ ប្រាជ្ញាមានតម្លៃលើសលប់។

ប្រាជ្ញាទទួលស្គាល់ថា ព្រះជាម្ចាស់បានបង្កើតយើង និងស្គាល់អ្វីដែលយើងគួរតែធ្វើ ដើម្បីរស់នៅឱ្យបានល្អ។ ព្រះពរ និងភាពមានលំនឹងនៅក្នុងជីវិតកើតចេញពីការរស់នៅតាមប្រាជ្ញារបស់ព្រះជាម្ចាស់នៅក្នុងគ្រប់ទំនាក់ទំនង។ ព្រះគម្ពីរផ្តល់ឱ្យយើងនូវការណែនាំផ្សេងៗជាច្រើនសម្រាប់ទំនាក់ទំនងចម្បងនិមួយៗ។ ឧទាហរណ៍ នៅក្នុងទំនាក់ទំនងខាងវិញ្ញាណរបស់យើង ព្រះគម្ពីរណែនាំយើងឱ្យអធិស្ឋានដោយអរព្រះគុណ មានសេចក្តីសង្ឃឹមលើព្រះគ្រីស្ទ លើកទឹកចិត្ត និងបម្រើគ្នាទៅវិញទៅមកដោយសេចក្តីស្រលាញ់ ព្រមទាំងជួបប្រជុំជាទៀងទាត់ជាមួយអ្នកជឿដទៃទៀត។ នៅក្នុងទំនាក់ទំនងរបស់យើងជាមួយពិភពលោកខាងសាច់ឈាម ព្រះគម្ពីរណែនាំយើងឱ្យអធិស្ឋានសម្រាប់អ្នកឈឺ និងឈប់ត្រេកត្រអាលតាមបំណងប្រាថ្នាដែលពោរពេញដោយបាប។ នៅក្នុងទំនាក់ទំនងខាងសង្គមរបស់យើង ព្រះគម្ពីរប្រាប់យើងអំពីរបៀបរស់នៅចុះសម្រុងនឹងគ្នា មានសេចក្តីស្រលាញ់ បន្ទាបខ្លួន ឱ្យពរមនុស្សដទៃទៀត រស់នៅដោយបង្កើតផលផ្លែ ខិតខំធ្វើការដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់អ្នកដទៃទៀត និងមានអត្តចរិតឱ្យអ្នកខាងក្រៅគោរព។

សូមរំលឹកឡើងវិញ។ ព្រះជាម្ចាស់បានដាក់ឱ្យមនុស្សមានទំនាក់ទំនងចម្បងបី គឺខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម។ ព្រះជាម្ចាស់បានប្រទានឱ្យយើងមានការណែនាំសម្រាប់ទំនាក់ទំនងនិមួយៗ។ ទំនាក់ទំនងទាំងនេះរកឃើញនៅក្នុងបទគម្ពីរ និងត្រូវបានស្គាល់ថាជា "ប្រាជ្ញា"។ ការរីកចម្រើនឡើងខាងឯប្រាជ្ញាតំណាងឱ្យការរៀន និងការ

ស្ដាប់បង្គាប់តាមផ្លូវ ការណែនាំ គោលបំណង និងបញ្ញត្តិរបស់ព្រះជាម្ចាស់សម្រាប់ទំនាក់ទំនងខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គមរបស់យើង។ នៅពេលដែលយើងស្ដាប់បង្គាប់តាមប្រាជ្ញារបស់ព្រះជាម្ចាស់សម្រាប់ទំនាក់ទំនងចម្បងទាំងនេះ យើងកាន់តែមានលំនឹងឡើង និងធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គ។ យើងអាចធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង នៅពេលដែលប្រាជ្ញានៅក្នុងព្រះគម្ពីរដឹកនាំគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់យើង។

លោក បប់ ម៉ូហ្វិត បានបង្រៀនគំរូអំពីការរីកចម្រើនឡើងរបស់ព្រះយេស៊ូវដល់បេសកជនប្រេស៊ីលមួយក្រុមនៅក្នុងឆ្នាំ ១៩៩០។ សិស្សពីរនាក់គឺជាស្ត្រីដែលនៅលីវ និងបម្រើព្រះនៅក្នុងចំណោមកុលសម្ព័ន្ធដាច់ស្រយាលមួយហៅថា សាតឺរេ ជាជនជាតិឥណ្ឌាភាគតិចរស់នៅតាមដងទន្លេអាម៉ាហ្សូន។ ជនជាតិទាំងនេះរៀនបានតិច ដូច្នេះស្ត្រីទាំងពីរនាក់បានបង្រៀនអំពីការរីកចម្រើនឡើងរបស់ព្រះយេស៊ូវនៅក្នុងផ្នែកទាំងបួន ដោយប្រើរឿង និងរូបភាព។ ក្រោយពីបានបង្រៀនជនជាតិសាតឺរេរួចហើយ បេសកជនទាំងនោះបានសូមឱ្យពួកគេជ្រើសរើសផ្នែកមួយក្នុងចំណោមផ្នែកទាំងបួនដែលពួកគេចង់រីកចម្រើនឡើង។ អ្នកដឹកនាំបានកើតចេញមក។ ជនជាតិតាមដងទន្លេនេះបានយល់ច្បាស់ហើយបានតែងតាំងអ្នកដឹកនាំបួននាក់ឱ្យគ្រប់គ្រងអ្នកភូមិរស់នៅតាមផ្នែកទាំងបួននៅក្នុងលូកា ២:៥២។ អ្នកដែលត្រូវបានគេជ្រើសរើសឱ្យដឹកនាំការអភិវឌ្ឍន៍ខាងសាច់ឈាមទទួលខុសត្រូវផ្នែកកសិកម្មភូមិ។ អ្នកដឹកនាំម្នាក់ផ្សេងទៀតត្រូវបានឱ្យមើលខុសត្រូវខាងប្រាជ្ញា និងបានចាប់ផ្ដើមសាលាមត្តេយ្យ ថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ និងថ្នាក់ដេរប៉ាក់។ អ្នកដឹកនាំសម្រាប់ផ្នែកខាងវិញ្ញាណធ្វើជាគ្រូគង្វាលពួកជំនុំមូលដ្ឋាន។ អ្នកដឹកនាំផ្នែកសង្គមទទួលខុសត្រូវឱ្យមានគំនិតថ្មីនៅក្នុងភូមិ។ ម្នាក់ក្នុងចំណោមអ្នកដឹកនាំទាំងនេះបានក្លាយទៅជាបេសកជន បង្រៀនទស្សនៈវិស័យនេះដល់អ្នកនៅក្នុងកុលសម្ព័ន្ធរបស់ខ្លួនតាមដងទន្លេ ទាំងផ្នែកខាងលើ និងផ្នែកខាងក្រោម។ ដើម្បីកសាងប្រាជ្ញាផងដែរ ស្ត្រីម្នាក់ត្រូវបានបណ្ដុះបណ្ដាលឱ្យធ្វើជាគ្រូបង្រៀននៅក្នុងសហគមន៍។ សហគមន៍បានចាប់ផ្ដើមសាលាមត្តេយ្យ ថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ និងថ្នាក់ដេរប៉ាក់[២]។

ដោយគ្រាន់តែស្វែងរក រៀន និងស្គាល់ប្រាជ្ញា នោះមិនគ្រប់គ្រាន់ឡើយ គឺត្រូវតែស្ដាប់បង្គាប់តាមប្រាជ្ញា។ យើងត្រូវរៀនអំពីការណែនាំរបស់ព្រះជាម្ចាស់ ដោយមានបំណងស្ដាប់បង្គាប់តាម និងធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គសម្រាប់ជីវិត និងការបម្រើរបស់យើង។ គ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់យើងត្រូវរស់នៅដោយដឹងថា ព្រះជាម្ចាស់បានប្រទានឱ្យយើងមានការបើកសំដែងរបស់ព្រះអង្គសម្រាប់ការរស់នៅ និងដោយដឹងថា

---

[2] ដកស្រង់នៅក្នុង *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* ទំព័រ ២៤៣។

ព្រះអង្គសង្កេតមើលយើង នៅពេលដែលយើងរស់នៅ។ យើងត្រូវតែរស់នៅតាមប្រាជ្ញា! កណ្ឌគម្ពីរយ៉ាកុបគាំទ្រសេចក្តីដែលយើងកំពុងតែមើលមកដល់ពេលនេះនៅក្នុងសញ្ញាចាស់អំពីប្រាជ្ញា:

> ក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាមានប្រាជ្ញានឹងយោបល់ ត្រូវឱ្យអ្នកនោះសំដែងចេញជាកិរិយាល្អ ដោយសារការដែលខ្លួនប្រព្រឹត្ត ដោយសេចក្តីសុភាពនៃប្រាជ្ញាចុះ...តែប្រាជ្ញាដែលមកពីស្ថានលើ នោះមុនដំបូងហៅថាបរិសុទ្ធ រួចមកមានមេត្រីចិត្ត សេចក្តីសំឡូត ចិត្តទន់ ក៏ពេញដោយសេចក្តីមេត្តាករុណា និងផលល្អ ឥតរើសមុខ ហើយឥតពុតមាយាផង (យ៉ាកុប ៣:១៣, ១៧)។

ប្រាជ្ញាមានតម្លៃខ្លាំងណាស់! ប៉ុន្តែ ប្រសិនបើយើងធ្វេសប្រហែសចំពោះការណែនាំរបស់ព្រះជាម្ចាស់ យើងនាំយកសេចក្តីហិនវិនាស និងភាពគ្មានលំនឹងចូលមកក្នុងទំនាក់ទំនងខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គមរបស់យើង។ ចោទិយកថា ៣០:១៥-១៦ ពន្យល់បន្ថែមទៀតអំពីការយកចិត្តទុកដាក់ចំពោះការណែនាំរបស់ព្រះជាម្ចាស់ជាបន្ទាន់។

> មើល នៅថ្ងៃនេះ អញបានដាក់សំញែងជីវិតនឹងសេចក្តីល្អនៅមុខឯង ព្រមទាំងសេចក្តីស្លាប់នឹងសេចក្តីអាក្រក់ផង ដោយអញបង្គាប់ដល់ឯងនៅថ្ងៃនេះ ឱ្យស្រឡាញ់ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងដើរតាមផ្លូវទ្រង់ ហើយនឹងកាន់តាមអស់ទាំងសេចក្តីបង្គាប់ នឹងច្បាប់ ហើយនឹងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ប្រយោជន៍ឱ្យឯងបានរស់នៅ ហើយចំរើនឡើង ហើយប្រយោជន៍ឱ្យព្រះយេហូវ៉ា ជាព្រះនៃឯងបានប្រទានពរដល់ឯងនៅក្នុងស្រុក ដែលឯងនឹងចូលទៅចាប់យកនោះ។

ក្នុងនាមជាអ្នកដឹកនាំ យើងមានសារដែលត្រូវប្រាប់! យើងអាចប្រាប់ លើកទឹកចិត្ត និងបណ្តុះបណ្តាលអ្នកជឿដទៃទៀតឱ្យអភិវឌ្ឍប្រាជ្ញា និងភាពមានលំនឹងនៅក្នុងទំនាក់ទំនងនិមួយៗនេះ។ នៅពេលដែលពួកគេរៀន និងស្តាប់បង្គាប់តាមប្រាជ្ញារបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ពួកគេនឹងធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះអង្គសម្រាប់ជីវិតរបស់ពួកគេ។ តាមពិតទៅ ប្រសិនបើការបម្រើរបស់យើងមានគោលដៅជួយមនុស្សឱ្យធ្វើដំណើរឆ្ពោះទៅរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត នោះត្រូវតែប្រាប់គេអំពីប្រាជ្ញារបស់ព្រះជាម្ចាស់!

## ប្រាជ្ញា និងទំនាក់ទំនងទាំងបី

ដោយព្រោះយើងមានទំនាក់ទំនងបី និងដោយព្រោះព្រះយេស៊ូវគឺជាគំរូរបស់យើង យើងអាចរៀបចំផែនការបម្រើដែលប៉ះពាល់ផ្នែកនិមួយៗ។ ចូរពិចារណាអំពីឧទាហរណ៍មួយដែលដាក់បញ្ចូលទំនាក់ទំនងទាំងបី និងប្រាជ្ញាចូលគ្នា។ ប្រសិនបើពួកជំនុំឧបត្ថម្ភការប្រកួតបាល់ទាត់រវាងក្រុមនៅក្នុងពួកជំនុំ ជាមួយនឹងក្រុមមកពីសហគមន៍ លទ្ធផលដែលចង់បានគួរតែជាការមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងផ្នែកសង្គម។ ប្រសិនបើពួកជំនុំបម្រើទឹកឱ្យកីឡាករ មានឥទ្ធិពលបន្ទាប់បន្សំនៅក្នុងផ្នែកខាងសាច់ឈាម។ ប្រសិនបើគ្រូបង្វឹកសុំព្រះជាម្ចាស់ប្រទានពរដល់ការប្រកួតរបស់ក្រុមទាំងពីរ មានឥទ្ធិពលបន្ទាប់បន្សំនៅក្នុងផ្នែកខាងវិញ្ញាណ។ ចុងបញ្ចប់ ប្រសិនបើគាត់ពិនិត្យមើលច្បាប់ប្រកួត ហើយលើកឡើងរបៀបដែលព្រះជាម្ចាស់ចង់ឱ្យយើងធ្វើតាមច្បាប់របស់ព្រះអង្គសម្រាប់ការប្រកួតនៅក្នុងជីវិត មានឥទ្ធិពលបន្ទាប់បន្សំដែលបានគ្រោងទុកនៅក្នុងផ្នែកប្រាជ្ញា។ រួមគ្នាមក ព្រឹត្តិការណ៍នេះគឺជាគំរូអំពីទំនាក់ទំនងរបស់យើងនៅក្នុងផ្នែកនិមួយៗ និងប្រាជ្ញា។

យើងមិនអាចរីកចម្រើនឡើងឆ្ពោះទៅរកគំរូរបស់ព្រះគ្រីស្ទ ដោយមិនមានប្រាជ្ញារបស់ព្រះជាម្ចាស់បានទេ។ មនុស្សគួរតែមើលឃើញប្រាជ្ញានោះតាមរយៈជីវិតរបស់យើង មានបទពិសោធន៍ជាមួយប្រាជ្ញានោះតាមរយៈការបម្រើរបស់យើង និងស្ដាប់ឮប្រាជ្ញានោះតាមរយៈពាក្យសំដីរបស់យើង។ អ្នកសរសេរទំនុកដំកើងប្រាប់យើងថា យើងអាចមានប្រាជ្ញាជាងខ្មាំងសត្រូវរបស់យើង ដោយព្រោះយើងមានប្រាជ្ញារបស់ព្រះជាម្ចាស់នៅជាមួយ។ យើងអាចមានយោបល់លើសជាងគ្រូរបស់យើង ដោយព្រោះយើងសញ្ជឹងគិតអំពីក្រឹត្យវិន័យរបស់ព្រះអង្គ ហើយយើងអាចយល់ច្រើនជាងពួកចាស់ៗ ដោយព្រោះយើងធ្វើតាមបញ្ញត្តិរបស់ព្រះអង្គ (ទំនុកដំកើង ១១៩:៩៧-១០០)។ ប្រាជ្ញាមិនមែនសម្រាប់តែយើងប៉ុណ្ណោះទេ! យើងអាចអធិស្ឋានឱ្យអ្នកដទៃ និងមានឥទ្ធិពលលើអ្នកដទៃឱ្យស្ដាប់បង្គាប់តាមប្រាជ្ញារបស់ព្រះអង្គ។ អ្នកដែលស្ដាប់បង្គាប់ព្រះអង្គរស់នៅដោយស័ក្តិសម និងគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់!

ស្នាព្រះហស្ដដែលព្រះជាម្ចាស់បានបង្កើតសុទ្ធតែល្អ ប៉ុន្តែអំពើបាបបានចូលមកក្នុងពិភពលោក ហើយទំនាក់ទំនងទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតសម្រាប់មនុស្សបានបាក់បែក គឺខាងវិញ្ញាណ ខាងសាច់ឈាម និងខាងសង្គម។ ភស្តុតាងមាននៅគ្រប់ទីកន្លែង! ប៉ុន្តែព្រះជាម្ចាស់មានផែនការស្ដាររបស់សព្វសារពើដែលបានបាក់បែកនោះឡើងវិញ។ ដោយសារសេចក្ដីសប្បុរសរបស់ព្រះអង្គ ព្រះអង្គបានប្រទានឱ្យយើងមានប្រាជ្ញារបស់ព្រះអង្គ ដើម្បីនាំយើង និងអ្នកដែលយើងបម្រើធ្វើដំណើរឆ្ពោះទៅរកការស្ដារឡើងវិញ និងការប្រោសឱ្យជាដែលព្រះអង្គចង់បានសម្រាប់ពិភពលោកដែលព្រះអង្គបានបង្កើត និងស្រលាញ់។ សូមឱ្យយើងស្វែងរកប្រាជ្ញារបស់ព្រះ ឱ្យតម្លៃដល់ប្រាជ្ញារបស់ព្រះ និងស្ដាប់បង្គាប់តាមប្រាជ្ញារបស់ព្រះ!

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ  85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាម ទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១000 ច្បាប់ ។*

# ធនធានល្អំដែលបានផ្តល់ជាយោបល់ជូន៖


Miller, Darrow L. and Bob Moffitt. *On Earth As It Is in Heaven.* DVD: Session ??. Available through Disciple Nations Alliance: www.disciplenations.org/resources.

Disciple Nations Alliance online course: www.disciplenations.org/resources/course. Section: Wholistic Ministry

Harvest Foundation. *Leadership Develop Training Program (Need to get this from Karla and change name to LCMT) Level Level ??,* pp.108 - 127. (Free download at www.harvestfoundation.org: Section: Material. Lesson is also called Three Relationships.

Moffitt, Bob, Tesch, Karla. *If Jesus Were Mayor: How Your Local Church Can Transform Your Community.* Oxford, UK: Monarch Books, 2006, pp. 53-55; 63 - ?.